# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ហិរញ្ញវត្ថុ
## សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
## 3ខែ និង 12ខែ ដែលបានបញ្ចប់
## ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
## និង
## របាយការណ៍របស់សវនករឯករាជ្យ
## ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
## សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | រ៉ូយ៉ាល់ រេលវេ ម.ក. | |
| លេខចុះបញ្ជីពាណិជ្ជកម្ម | 00018504 | |
| ទីស្នាក់ការចុះបញ្ជី | ស្ថានីយ៍រថភ្លើងភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី<br>សង្កាត់ស្រះចក ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)<br>អ្នកឧកញ៉ា គិត ម៉េង | |
| ក្រុមប្រឹក្សាភិបាល | អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| | លោក Paul Clements | អភិបាល |
| | លោក លន់ យ៉េង | អភិបាលឯករាជ្យ |
| អ្នកគ្រប់គ្រង | លោក John Guiry | នាយកប្រតិបត្តិ |
| | លោកស្រី តូច សុធីតា | នាយិកា ផ្នែកពាណិជ្ជកម្ម |
| | លោក ឌី ចិត្រា | នាយកប្រតិបត្តិផ្នែកហិរញ្ញវត្ថុ |
| គណៈកម្មាធិការសវនកម្ម និងហានិភ័យ | លោក លន់ យ៉េង | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| គណកម្មាធិការតែងតាំង និងលាភការ | លោក William Mark Hanna | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| ធនាគារិកចម្បង | ធនាគារ វីង (ខេមបូឌា) ម.ក | |
| សវនករ | អេហ្វអាយអាយ & អឹសូស៊ីអេត | |

**រ៉ូយ៉ាល់ រេលវេ ម.ក.**

# មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 6 |
| 2. | របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 7 – 9 |
| 3. | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 10 – 11 |
| 4. | របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សង្ខេបចន្លោះពេល | 12 – 13 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 14 |
| 6. | របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 15 – 16 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 17 – 62 |

ROYAL RAILWAY

**ROYAL RAILWAY PLC.**
Central Railway Station, Sangkat Sras Chork, Daun Penh, Phnom Penh, Cambodia
T +885 23 992 379
F +885 23 992 353
www.royal-railway.com

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") សូមធ្វើការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺពាក់ព័ន្ធនឹងសេវាកម្មផ្លូវដែក ដែលរួមមានសេវាកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរតាមផ្លូវដែក ព្រមទាំងផ្តល់ជូននូវសេវាដឹកជញ្ជូនដោយមធ្យោបាយផ្សេងទៀត ក្នុងករណីដែលការដឹកជញ្ជូនតាមរថភ្លើងមិនអាចប្រព្រឹត្តិទៅបាន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក និងគ្រឿងបរិក្ខារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។ សូមមើលទំព័រទី12 និង 13។

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់អនុសាសន៍ឱ្យមានការទូទាត់ភាគលាភនាកាលបរិច្ឆេទនៃរបាយការណ៍នេះដែរ។

## ដើមទុន

ពុំមានការផ្លាស់ប្តូររចនាសម្ព័ន្ធនៃការកាន់កាប់ដើមទុនក្នុងអំឡុងការិយបរិច្ឆេទ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## របាយការណ៍ របស់ម.ក.

### ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឱ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឱ្យចំនួននៃគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឱ្យប្រាកដថា បណ្តាទ្រព្យសកម្មលើកលែងបំណុល ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងបានធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- លើកលែងតែការបង្ហាញនៅក្នុងកំណត់សម្គាល់ 29 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ពុំមានបំណុលយថាហេតុណាមួយ ដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

# របាយការណ៍ របស់ ក.ភ.

**បំណុលយថាភាព និងបំណុលផ្សេងៗ (ត)**

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឱ្យសង ឬអាចនឹងទាមទារឱ្យសងក្នុងអំឡុងកាលបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឱ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់នោះឡើយ។

**ការផ្លាស់ប្តូរនៃកាលៈទេសៈ**

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

**ព្រឹត្តិការណ៍ក្នុងអំឡុងការិយបរិច្ឆេទ និងចាប់តាំងពីកាលបរិច្ឆេទរាយការណ៍**

ចាប់តាំងពីថ្ងៃទី30 ខែមិថុនា ឆ្នាំ2024 រហូតដល់បច្ចុប្បន្ននេះ ក្រុមហ៊ុនមិនអាចអនុលោមបានតាមកិច្ចព្រមព្រៀងចំនួន 4 ចំណុច រួមមាន អនុបាតទូទាត់បំណុល អនុបាតប្រតិបត្តិការ អនុបាតបំណុលធៀបទៅនឹងចំណេញមុនដកពន្ធ ការប្រាក់និងរំលស់ ("EBITDA") និងអនុបាតបំណុលសរុបធៀបនឹងទ្រព្យសកម្មសរុប ដែលបានកំណត់ក្រោមកិច្ចព្រមព្រៀងធានាមូលបត្របំណុល។ សូមមើលកំណត់សម្គាល់15។

ក្រុមហ៊ុន បានជូនដំណឹងដល់ក្រុមហ៊ុនធានា GuarantCo Ltd ហៅកាត់ថា ("អ្នកធានា") លើចំណុចដែលមិនបានបំពេញខាងលើនៅថ្ងៃទី3 ខែតុលា ឆ្នាំ2025 និងបានធ្វើបច្ចុប្បន្នភាពគំរូការព្យាករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ផ្អែកតាមតម្រូវការរបស់អ្នកធានា។ នៅថ្ងៃទី13 ខែមករា ឆ្នាំ2026 អ្នកធានាបានធ្វើការឆ្លើយតបត្រឡប់មកវិញដោយយល់ព្រមក្នុងការលើកលែងពីការមិនអាចបំពេញបានតាមតម្រូវការអនុលោមភាពខាងលើ យោងទៅតាមសំណើស្នើសុំការលើកលែងនៅថ្ងៃទី4 ខែកក្កដា ឆ្នាំ2025។ លើសពីនេះទៅទៀត ក្រុមហ៊ុនក៏បាននឹងកំពុងរៀបចំលិខិតស្នើសុំការលើកលែងពីតម្រូវការអនុលោមភាពគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ទៅកាន់អ្នកធានា ប៉ុន្តែការរៀបចំមិនទាន់រួចរាល់នៅឡើយ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

# រ៉ូយ៉ាល់ គ្រុបភ្នំពេញ ម.ក.

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលយល់ឃើញថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Raymond Thornton Yager | អភិបាល |
| លោក William Mark Hanna | អភិបាល |
| លោក Paul Clements | អភិបាល |
| លោក លន់ យ៉េង | អភិបាលឯករាជ្យ |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានអភិបាលណាមួយកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល ក្រៅពីអ្នកឧកញ៉ា គិត ម៉េង ដែលជាប្រធានក្រុមប្រឹក្សាភិបាលមានកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ផង និងដោយប្រយោលផង តាមរយៈក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ បានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឱ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃទៀយ។

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលក្នុងចំនួនសរុប ដែលបានទទួល ឬដល់ពេលកំណត់ និងអាចទទួលបានដោយអភិបាល ដូចដែលបានដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រ៉ូយ៉ាល់ គ្រុប ម.ក.

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែដែលបានបញ្ចប់ ដូចបានបង្ហាញនៅ ទំព័រទី 10 ដល់ទី62 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("ស.គ.អ.ក 34")*។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឱ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយ ស.គ.អ.ក 34 ឬប្រសិនបើមានវៀរចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឱ្យប្រាកដថា ការវៀរចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- ត្រួតពិនិត្យដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ហើយរក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។
- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសកម្មរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ខ្ញុំបាទ តំណាងឱ្យក្រុមប្រឹក្សាភិបាលនៃ រ៉ូយ៉ាល់ រេលវេ ម.ក. សូមជូនមតិថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយត្រូវបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34 *"របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"*។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

**អ្នកឧកញ៉ា គិត ម៉េង**

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦.

Fii

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ
# របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
# ជូនចំពោះភាគទុនិករបស់
# វ៉ូយ៉ាល់ រេលវេ ម.ក.

## សេចក្តីផ្តើម

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន វ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី62 ហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល") ដែលរួមមានៈ

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
- របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025
- កំណត់សម្គាល់ពន្យល់ផ្សេងៗទៀតទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *"របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី23 ខែមីនា ឆ្នាំ2025 ថារបាយការណ៍នោះជាសារវន្តមានភាពត្រឹមត្រូវ។ យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ទៅលើព័ត៌មានប្រៀបធៀបសម្រាប់ត្រីមាសដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដែលព័ត៌មានទាំងនោះមិនបានរងសវនកម្មនោះទេ ប៉ុន្តែត្រូវបានធ្វើការត្រួតពិនិត្យ ដោយសវនករដដែល ដែលបានបញ្ចេញសេចក្តីសន្និដ្ឋានត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនៅថ្ងៃទី14 ខែកុម្ភៈ ឆ្នាំ2025។

# របាយការណ៍របស់សវនករឯករាជ្យស្ដីពីការត្រួតពិនិត្យលើ
# របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
# ជូនចំពោះភាគទុនិករបស់
# វ៉ូយ៉ាល់ រេលវេ ម.ក.

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី "*ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មានជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឱ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះ យើងខ្ញុំមិនបញ្ចេញមតិសវនកម្មនោះទេ។

## សេចក្តីសន្និដ្ឋាន

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឱ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្តស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "*របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*" នោះឡើយ។

## ការទាញចំណាប់អារម្មណ៍លើបញ្ហា

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ 29.1 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលបញ្ជាក់អំពីកម្រៃសម្បទានត្រូវបង់ទៅរាជរដ្ឋាភិបាលកម្ពុជា តាមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ សម្រាប់ការប្រើប្រាស់ទ្រព្យសម្បទាន ចាប់ពីកាលបរិច្ឆេទប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទាន។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន បានធ្វើការវាយតម្លៃលើកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ ហើយជឿជាក់ថាកាតព្វកិច្ចក្នុងការទូទាត់ថ្លៃសម្បទាននេះពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនកំពុងបន្តការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាទៅលើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានថ្មី។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនជឿជាក់ថាចំនួន និងពេលវេលានៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចនៅមិនទាន់អាចប៉ាន់ស្មានដោយជឿជាក់បាន ដោយសារតែកាលបរិច្ឆេទប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទានមិនត្រូវបានកំណត់នៅឡើយ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នេះ។ លទ្ធផលចុងក្រោយនៃបញ្ហានេះ គឺមានលក្ខណៈមិនប្រាកដប្រជា អាស្រ័យហេតុនេះ ពុំមានសំវិធានធនណាមួយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទេ។ ការសន្និដ្ឋានរបស់យើងខ្ញុំ មិនត្រូវបានកែប្រែដោយសារបញ្ហានេះឡើយ។

**របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ**
**របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**

**ជូនចំពោះភាគទុនិករបស់**

**រ៉ូយ៉ាល់ រេលវេ ម.ក.**

តំណាងក្រុមហ៊ុន អេហ្វអាយអាយ & អឺសូស៊ីអេត

ព្រះរាជាណាចក្រកម្ពុជា
អេហ្វអាយអាយ & អឺសូស៊ីអេត
Fii&Associates Co.,Ltd
ទីស្នាក់ការរាជធានីភ្នំពេញ

______________________

**សេខ ចាន់ថន**
*ដៃគូសវនករ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ2026

# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេស.អ៊ី.ហ្ស៊េដ (ហ្ស៊េដ) ម.ក.

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | 5 | 1,458,250 | 5,851,956 | 4,726,176 | 19,022,858 |
| គណនីអតិថិជន និង គណនីត្រូវទទួលផ្សេងៗ | 6 | 1,097,746 | 4,405,255 | 2,427,248 | 9,769,673 |
| សន្និធិ | 7 | 139,101 | 558,212 | 94,926 | 382,077 |
| | | 2,695,097 | 10,815,423 | 7,248,350 | 29,174,608 |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| សមតុល្យនៅធនាគារ | 5 | 3,785,587 | 15,191,561 | 4,153,643 | 16,718,413 |
| គណនីត្រូវទទួលផ្សេងៗ | 8 | 1,957,595 | 7,855,829 | 1,583,398 | 6,373,177 |
| ទ្រព្យ និងបរិក្ខារ | 9 | 19,429,249 | 77,969,576 | 17,234,796 | 69,370,054 |
| ទ្រព្យសកម្មអរូបី | 10 | 223,746 | 897,893 | 239,741 | 964,958 |
| ទ្រព្យវិនិយោគ | 11 | 89,103 | 357,570 | 81,629 | 328,557 |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | 12 | 643,421 | 2,582,048 | 723,848 | 2,913,488 |
| | | 26,128,701 | 104,854,477 | 24,017,055 | 96,668,647 |
| **ទ្រព្យសកម្មសរុប** | | 28,823,798 | 115,669,900 | 31,265,405 | 125,843,255 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវទូទាត់ផ្សេងៗ | 13 | 4,659,089 | 18,696,924 | 3,447,482 | 13,876,115 |
| ប្រាក់កម្ចី | 14 | 13,983,392 | 56,115,352 | 6,800,576 | 27,372,318 |
| មូលបត្របំណុល | 15 | 21,333,701 | 85,612,142 | 24,987,523 | 100,574,780 |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 16 | 143,846 | 577,254 | 115,213 | 463,732 |
| បំណុលពន្ធអប្បបរមា | 24(ខ) | 13,616 | 54,641 | 12,021 | 48,385 |
| បំណុលភតិសន្យា | 17 | 46,628 | 187,118 | 37,589 | 151,296 |
| | | 40,180,272 | 161,243,431 | 35,400,404 | 142,486,626 |

# វ៉ូយ៉ាល់ គ្រុបមីម ម.ក.

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | កំណត់សម្គាល់ | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **បំណុលរយៈពេលវែង** | | | | | |
| មូលបត្របំណុល | 15 | 9,809,327 | 39,364,829 | 9,809,327 | 39,482,541 |
| ប្រាក់កម្ចី | 14 | 607,454 | 2,437,713 | 858,218 | 3,454,327 |
| សំវិធានធនលើកិច្ចសន្យាខាតបង់ | | 9,687 | 38,874 | 8,427 | 33,919 |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 16 | 30,614 | 122,854 | 42,191 | 169,819 |
| បំណុលភតិសន្យា | 17 | 690,493 | 2,770,948 | 737,122 | 2,966,916 |
| គណនីត្រូវទូទាត់ផ្សេងៗ | 18 | 220,713 | 885,721 | 228,373 | 919,201 |
| | | 11,368,288 | 45,620,939 | 11,683,658 | 47,026,723 |
| **បំណុលសរុប** | | 51,548,560 | 206,864,370 | 47,084,062 | 189,513,349 |
| **មូលធន** | | | | | |
| ដើមទុន | 19 | 13,020,930 | 52,083,720 | 13,020,930 | 52,083,720 |
| ប្រាក់ខាតបង្គរ | | (35,745,692) | (145,286,133) | (28,839,587) | (117,585,747) |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 2,007,943 | - | 1,831,933 |
| | | (22,724,762) | (91,194,470) | (15,818,657) | (63,670,094) |
| **បំណុល និងមូលធនសរុប** | | 28,823,798 | 115,669,900 | 31,265,405 | 125,843,255 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណូល | 20 | 13,814,708 | 55,410,794 | 11,286,614 | 45,947,806 |
| ថ្លៃដើមសេវាកម្ម | 21 | (17,355,115) | (69,611,366) | (13,605,458) | (55,387,820) |
| **ប្រាក់ខាតដុល** | | (3,540,407) | (14,200,572) | (2,318,844) | (9,440,014) |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 22 | 1,081,639 | 4,338,454 | 1,165,691 | 4,745,528 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | 23 | (1,116,676) | (4,478,987) | (2,653,745) | (10,803,396) |
| (សំវិធានធន)/តំហយលើការខាតបង់លើកិច្ចសន្យាខាតបង់ | | (1,260) | (5,054) | 43,881 | 178,640 |
| តំហយលើការខាតបង់លើឱនភាពនៃតម្លៃ | 5,6 | 14,173 | 56,848 | 67,609 | 275,236 |
| ចំណាយពន្ធអប្បបរមា | 25(គ) | (149,123) | (598,132) | (124,802) | (508,069) |
| **ប្រាក់ខាតប្រតិបត្តិការ** | | (3,711,654) | (14,887,443) | (3,820,210) | (15,552,075) |
| ចំណាយហិរញ្ញប្បទាន – សុទ្ធ | 26 | (3,194,451) | (12,812,943) | (4,336,061) | (17,652,105) |
| **ប្រាក់ខាតមុនដកពន្ធលើប្រាក់ចំណេញ** | | (6,906,105) | (27,700,386) | (8,156,271) | (33,204,180) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 25(គ) | - | - | - | - |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (6,906,105) | (27,700,386) | (8,156,271) | (33,204,180) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | |
| **ធាតុដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 176,010 | - | 834,933 |
| **ប្រាក់ខាតលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | (6,906,105) | (27,524,376) | (8,156,271) | (32,369,247) |

# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ ម.ក.

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|
| | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| ចំណូល | 20 | 3,787,176 | 15,205,512 | 2,973,751 | 12,022,875 |
| ថ្លៃដើមសេវាកម្ម | 21 | (4,435,489) | (17,808,488) | (3,509,535) | (14,189,050) |
| **ប្រាក់ខាតដុល** | | (648,313) | (2,602,976) | (535,784) | (2,166,175) |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 22 | 280,641 | 1,126,774 | 278,101 | 1,124,362 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | 23 | (330,419) | (1,326,632) | (710,336) | (2,871,888) |
| តំហាយលើកិច្ចសន្យាខាតបង់ | | - | - | 6,868 | 27,767 |
| តំហាយលើការខាតបង់លើឱនភាពនៃតម្លៃ | 5,6 | 31,770 | 127,557 | 28,708 | 116,066 |
| ចំណាយពន្ធអប្បបរមា | 25(គ) | (40,691) | (163,374) | (32,595) | (131,782) |
| **ប្រាក់ខាតប្រតិបត្តិការ** | | (707,012) | (2,838,651) | (965,038) | (3,901,650) |
| ចំណាយហិរញ្ញប្បទាន – សុទ្ធ | 26 | (707,443) | (2,840,384) | (1,186,591) | (4,797,388) |
| **ប្រាក់ខាតមុនដកពន្ធលើប្រាក់ចំណេញ** | | (1,414,455) | (5,679,035) | (2,151,629) | (8,699,038) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 25(គ) | - | - | - | - |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (1,414,455) | (5,679,035) | (2,151,629) | (8,699,038) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | |
| **ធាតុដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងរបាយការណ៍ចំណេញ ឬខាត** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 2,827 | - | 38,731 |
| **ប្រាក់ខាតលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | (1,414,455) | (5,676,208) | (2,151,629) | (8,660,307) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | ដើមទុន | | ប្រាក់ខាតបង្គរ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2025 | 13,020,930 | 52,083,720 | (28,839,587) | (117,585,747) | - | 1,831,933 | (15,818,657) | (63,670,094) |
| ***លទ្ធផលលម្អិតសរុប*** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (6,906,105) | (27,700,386) | - | - | (6,906,105) | (27,700,386) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 176,010 | - | 176,010 |
| | - | - | (6,906,105) | (27,700,386) | - | 176,010 | (6,906,105) | (27,524,376) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | 13,020,930 | 52,083,720 | (35,745,692) | (145,286,133) | - | 2,007,943 | (22,724,762) | (91,194,470) |
| | | | | | | | | |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2024 | 13,020,930 | 52,083,720 | (20,683,316) | (84,381,567) | - | 997,000 | (7,662,386) | (31,300,847) |
| ***លទ្ធផលលម្អិតសរុប*** | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (8,156,271) | (33,204,180) | - | - | (8,156,271) | (33,204,180) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 834,933 | - | 834,933 |
| | - | - | (8,156,271) | (33,204,180) | - | 834,933 | (8,156,271) | (32,369,247) |
| នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 13,020,930 | 52,083,720 | (28,839,587) | (117,585,747) | - | 1,831,933 | (15,818,657) | (63,670,094) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (6,906,105) | (27,700,386) | (8,156,271) | (33,204,180) |
| *និយ័តភាពលើ៖* | | | | |
| រំលស់ | 3,366,021 | 13,501,110 | 2,326,339 | 9,470,526 |
| ចំណាយការប្រាក់ | 3,300,639 | 13,238,863 | 4,663,827 | 18,986,440 |
| អត្ថប្រយោជន៍និយោជិត | 253,929 | 1,018,509 | 210,332 | 856,262 |
| ការលុបចោលទ្រព្យ និងបរិក្ខារ | 4,967 | 19,923 | 418 | 1,702 |
| ចំណាយពន្ធអប្បបរមា | 149,123 | 598,132 | 124,802 | 508,069 |
| ចំណូលការប្រាក់ | (106,188) | (425,920) | (327,766) | (1,334,335) |
| សំវិធានធន/(តំហាយ)លើកិច្ចសន្យាខាតបង់ | 1,260 | 5,054 | (43,881) | (178,640) |
| តំហាយលើការខាតបង់លើឱនភាពនៃតម្លៃ | (14,173) | (56,848) | (67,609) | (275,236) |
| | 49,473 | 198,437 | (1,269,809) | (5,169,392) |
| *បម្រែបម្រួលនៃ៖* | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | 1,315,472 | 5,276,358 | 458,070 | 1,864,803 |
| សន្និធិ | (44,175) | (177,186) | 59,676 | 242,941 |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | 1,211,607 | 4,859,756 | 744,975 | 3,032,793 |
| គណនីត្រូវទទួលផ្សេងៗ | (374,197) | (1,500,904) | (1,583,398) | (6,446,013) |
| គណនីត្រូវទូទាត់ផ្សេងៗ | (7,660) | (30,724) | 228,373 | 929,706 |
| សាច់ប្រាក់ទទួលបានពី/(ប្រើប្រាស់ក្នុង) ប្រតិបត្តិការ | 2,150,520 | 8,625,737 | (1,362,113) | (5,545,162) |
| ការប្រាក់បានបង់ | (2,815,587) | (11,293,319) | (3,586,054) | (14,598,826) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (236,873) | (950,098) | (199,817) | (813,455) |
| ពន្ធអប្បរមាបានបង់ | (147,528) | (591,735) | (121,944) | (496,434) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | (1,049,468) | (4,209,415) | (5,269,928) | (21,453,877) |

## រ៉ូយ៉ាល់ គ្រុបភ្នំពេញ ម.ក.

### របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
### សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|
| | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការប្រាក់បានទទួល | 474,244 | 1,902,193 | 132,973 | 541,333 |
| ការទិញទ្រព្យ និងបរិក្ខារ | (5,455,452) | (21,881,818) | (10,628,551) | (43,268,831) |
| ការទិញទ្រព្យសកម្មអរូបី | - | - | (5,648) | (22,993) |
| ការទិញទ្រព្យវិនិយោគ | (21,041) | (84,395) | (8,604) | (35,027) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (5,002,249) | (20,064,020) | (10,509,830) | (42,785,518) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | 7,109,896 | 28,517,793 | 3,233,054 | 13,161,763 |
| ការទូទាត់ប្រាក់កម្ចី | (229,098) | (918,912) | (208,989) | (850,794) |
| ការទូទាត់មូលបត្របំណុល | (4,020,209) | (16,125,058) | - | - |
| ការទូទាត់បំណុលភតិសន្យា | (105,001) | (421,159) | (100,000) | (407,100) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 2,755,588 | 11,052,664 | 2,924,065 | 11,903,869 |
| **ការថយចុះសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (3,296,129) | (13,220,771) | (12,855,693) | (52,335,526) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | 4,794,130 | 19,296,373 | 17,649,823 | 72,099,527 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (64,125) | - | (467,628) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** (កំណត់សម្គាល់ 5) | 1,498,001 | 6,011,477 | 4,794,130 | 19,296,373 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

កំណត់សម្គាល់ទាំងនេះ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## 1. ព័ត៌មានអំពីក្រុមហ៊ុន

រ៉ូយ៉ាល់ រេលវេ ម.ក. (ហៅកាត់ថា "ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដំបូង ក្រោមលេខបញ្ជីពាណិជ្ជកម្ម Co. 2874/06E ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2006 ចេញដោយក្រសួងពាណិជ្ជកម្ម។ បន្ទាប់មកក្រុមហ៊ុនបានទទួលការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីក្លាយជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ("QIP") ដែលមានលេខចុះបញ្ជីថ្មី 0643KH/2014 ចុះថ្ងៃទី6 ខែតុលា ឆ្នាំ2015។ នៅថ្ងៃទី25 ខែសីហា ឆ្នាំ2016 ក្រុមហ៊ុនបានចុះបញ្ជីឡើងវិញ និងទទួលលេខបញ្ជីពាណិជ្ជកម្មថ្មីគឺ 00018504 ពីក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនដំណើរការសេវាកម្មផ្លូវដែក ក្រោមកិច្ចព្រមព្រៀងសម្បទានផ្លូវដែក ("កិច្ចព្រមព្រៀងសម្បទាន") ជាមួយរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីផ្តល់សេវាកម្មផ្លូវដែកនៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល 30ឆ្នាំ ទៅលើទ្រព្យសកម្មសម្បទានជាក់លាក់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងសម្បទាន។ ប៉ុន្តែកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងសម្បទាន គឺមិនទាន់បានកំណត់ជាផ្លូវការនោះទេ ដោយសារតែលក្ខខណ្ឌមុនកាលបរិច្ឆេទចូលជាធរមាននៅពុំទាន់បានបំពេញទាំងស្រុងនៅឡើយ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ក្រុមហ៊ុននៅតែបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានផ្លូវដែកថ្មី។

ភាគហ៊ុនរបស់ក្រុមហ៊ុន 98.9999% ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) និង 1.0001% ទៀតជាកម្មសិទ្ធិរបស់អ្នកឧកញ៉ា គិត ម៉េង។

ការិយាល័យដែលបានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅស្ថានីយ៍ផ្លូវដែកកណ្តាល មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមានបុគ្គលិកចំនួន 1,054 នាក់ (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2024៖ មានបុគ្គលិក ចំនួន 964នាក់)។

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល*។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់ របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") នោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើសត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុនចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

# រ៉ូយ៉ាល់ គ្រុប ផតថ៍ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

### 2. មូលដ្ឋាននៃការរៀបចំ (ត)

### (ក) របាយការណ៍អនុលោមភាព (ត)

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ2026។

### (ខ) គោលនយោបាយគណនេយ្យសារវន្ត

គោលនយោបាយគណនេយ្យសារវន្ត ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2024។

### (គ) ការសន្មតនិរន្តរភាពអាជីវកម្ម

នៅក្នុងដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមានប្រាក់ខាតសុទ្ធចំនួន 6,906,105 ដុល្លារអាមេរិក និងសម្រាប់3ខែ ដែលបានបញ្ចប់ចំនួន 1,414,455 ដុល្លារអាមេរិក (ដំណាច់ការិយបរិច្ឆេទ 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ៖ 8,156,271 ដុល្លារអាមេរិក/ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ៖ 2,151,629 ដុល្លារអាមេរិក) និងគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 ក្រុមហ៊ុនមានបំណុលរយៈពេលខ្លីសុទ្ធចំនួន 37,485,175 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ៖ បំណុលរយៈពេលខ្លីសុទ្ធចំនួន 28,152,054 ដុល្លារអាមេរិក) ហើយគិតត្រឹមកាលបរិច្ឆេទនេះក្រុមហ៊ុនមានប្រាក់ខាតបង្គរចំនួន 35,745,692 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 ៖ 28,839,587 ដុល្លារអាមេរិក) ។ លើសពីនេះទៅទៀត ក្រុមហ៊ុនពុំអាចអនុលោមបានលើអនុបាតហិរញ្ញវត្ថុដែលតម្រូវការសម្រាប់មូលបត្របំណុលសាជីវកម្មទី2 (កំណត់សម្គាល់ 15)។

សុពលភាពនៃការសន្មតនិរន្តភាពអាជីវកម្មជាមូលដ្ឋាន គឺអាស្រ័យទៅលើការបន្តផ្តល់ជំនួយហិរញ្ញវត្ថុរបស់ភាគទុនិកដែលចាំបាច់ដើម្បីឱ្យក្រុមហ៊ុនអាចមានលទ្ធភាពក្នុងការទូទាត់បំណុលរបស់ខ្លួន នៅពេលដល់កំណត់ដែលត្រូវទូទាត់សង និងដើម្បីរក្សានិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុននាពេលអនាគត។ បន្ថែមទៀតនោះសុពលភាពនេះ ក៏ពឹងផ្អែកលើលទ្ធផល ដែលនឹងត្រូវសម្រេចឱ្យបានប្រកបដោយភាពជោគជ័យនៅក្នុងរយៈពេលជាអប្បបរមាទៅលើកិច្ចព្រមព្រៀងសម្បទាន រវាងរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមហ៊ុន។

នាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ភាគទុនិកបានបញ្ជាក់ពីការគាំទ្រផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់បន្តទៀតដល់ក្រុមហ៊ុន។ ក្រុមហ៊ុនក៏បន្តចូលរួមធ្វើកិច្ចការងារយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវកិច្ចព្រមព្រៀងសម្បទាននៅក្នុងរយៈពេលដែលបានកំណត់។

ដោយផ្អែកលើកត្តាទាំងនេះ អ្នកគ្រប់គ្រងមានការរំពឹងទុកដ៏សមហេតុផលថា ក្រុមហ៊ុននឹងមានធនធានគ្រប់គ្រាន់ដើម្បីបន្តប្រតិបត្តិការទៅអនាគតដែលអាចរំពឹងទុកបាន។

## 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

### (ឃ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែង អាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ប្រមាណ ត្រូវបានទទួលស្គាល់តាមវិធីសាស្រ្តទស្សនវិស័យ។ ការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងដោយអ្នកគ្រប់គ្រងក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន និងប្រភពសំខាន់ៗនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាន គឺដូចគ្នាទៅនឹងអ្វីដែលបានពណ៌នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ។

## 3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទាំងនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ចំនួនទាំងអស់ត្រូវបានបង្គត់ទៅដុល្លារអាមេរិកដែលនៅជិតបំផុត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះ ធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ .ក 21 – *ផលប៉ះពាល់នៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្រ្ត។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម នៅក្នុងការិយបរិច្ឆេទរាយការណ៍ ដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការដោយសារតែអត្រាប្តូររូបិយប័ណ្ណមិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 12ខែ ដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025

## 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល (ត)

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| ការិយបរិច្ឆេទហិរញ្ញវត្ថុ | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យមការិយបរិច្ឆេទ 3ខែ | អត្រាមធ្យមការិយបរិច្ឆេទ 12ខែ |
|---|---|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2025 | 1 ដុល្លារអាមេរិក = | 4,013រៀល | 4,015រៀល | 4,011រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2024 | 1 ដុល្លារអាមេរិក = | 4,025រៀល | 4,043រៀល | 4,071រៀល |

